**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករមូលបត្រកម្ពុជា**
លេខ: ០០៦/២១ ន.ម.ក./ត.លា.ន.

ថ្ងៃព្រហស្បតិ៍ ១១ កើត ខែ ចេត្រ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០២១

# គោលការណ៍ណែនាំ
# ស្ដីពី
# ការបែងចែកភាគលាភដល់ភាគហ៊ុនិក
# សម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

*****

យោងតាមព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន អនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្ដីពីការបំពេញបន្ថែមអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ប្រកាសលេខ ០១៧/១៨ គ.ម.ក.ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ប្រកាសលេខ ០០៧/១៨ គ.ម.ក./ប្រ.ក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការបង្ហាញព័ត៌មានសាជីវកម្ម ប្រកាសលេខ ០០៩/១០ គ.ម.ក./ប្រ.ក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ ស្ដីពីការទទួលស្គាល់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត ព្រមទាំងដើម្បីសម្រួលដល់ការយល់ដឹង ការការពារសិទ្ធិដល់វិនិយោគិនលើមូលបត្រកម្មសិទ្ធិ និងធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពតាមលក្ខខណ្ឌតម្រូវផ្នែកអភិបាលកិច្ចសាជីវកម្ម និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) សូមចេញគោលការណ៍ណែនាំស្ដីពី “ការបែងចែកភាគលាភដល់ភាគហ៊ុនិកសម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ” ដើម្បីឱ្យបុគ្គលចុះបញ្ជីលក់មូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ភ្នាក់ងារទូទាត់ និងបុគ្គលពាក់ព័ន្ធផ្សេងទៀតអនុវត្តតាមយន្តការ និងនីតិវិធីដូចខាងក្រោម÷

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវធ្វើការបែងចែកភាគលាភជូនភាគហ៊ុនិកយ៉ាងតិច ១ (មួយ) ដងក្នុងមួយឆ្នាំក្នុងករណីលទ្ធផលប្រតិបត្តិការរបស់បុគ្គលចុះបញ្ជីលក់មូលបត្រមានប្រាក់ចំណេញសុទ្ធ។ ក្នុងករណីចាំបាច់

អាសយដ្ឋាន: អគារ 168F ផ្លូវ 598 សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ-កម្ពុជា ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Address: Building 168F, Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Cambodia
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

ក្រុមប្រឹក្សាភិបាលអាចស្នើសុំការសម្រេចពីមហាសន្និបាតភាគហ៊ុនិក ដើម្បីរក្សាទុកប្រាក់ចំណេញសុទ្ធមួយផ្នែក ឬទាំងស្រុងក្នុងគោលដៅនៃការវិនិយោគ ឬគោលដៅច្បាស់លាស់ផ្សេងទៀត។ ករណីនេះបុគ្គលចុះបញ្ជីលក់មូលបត្រត្រូវជូនដំណឹងមក **ន.ម.ក.** និងផ្សព្វផ្សាយជាសាធារណៈដល់ភាគហ៊ុនិក។

បុគ្គលចុះបញ្ជីលក់មូលបត្រអាចបែងចែកភាគលាភ ជាសាច់ប្រាក់ និង/ឬមូលបត្រ ដោយគោរពតាមនីតិវិធីដូចខាងក្រោម÷

១-ការសម្រេចពីការប្រកាសបែងចែកភាគលាភ ជាសាច់ប្រាក់ និង/ឬមូលបត្រ ត្រូវធ្វើឡើងតាមរយៈសេចក្ដីសម្រេចមហាសន្និបាតភាគហ៊ុនិកតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ឬអនុវត្តតាមលក្ខន្តិកៈក្រុមហ៊ុន។

២-បន្ទាប់ពីមានការសម្រេចអំពីការបែងចែកភាគលាភនេះ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវជូនដំណឹងដល់ភាគហ៊ុនិក និងជូនដំណឹងក្នុងពេលដំណាលគ្នាមក **ន.ម.ក.** នូវព័ត៌មានដូចខាងក្រោម÷

-ប្រភេទនៃភាគលាភដែលត្រូវបែងចែក

-ប្រភពនៃភាគលាភ

-ចំនួនដងនៃការបែងចែកភាគលាភក្នុងមួយឆ្នាំ (បែងចែកភាគលាភជាប្រចាំត្រីមាស ប្រចាំឆមាស ឬប្រចាំឆ្នាំ)

-អនុបាតនៃការបែងចែកភាគលាភ

-ភាគលាភសរុបដែលត្រូវបែងចែក

-ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ

-ការបង្កើនផេដអាប់ខេបភីថល (Paid up capital)

-កាលបរិច្ឆេទអិចឌីវិដឹនដ៍ (Ex-Dividend) ឬអិចរាយដ៍ (Ex-Right)

-កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ (Record date)

-កាលបរិច្ឆេទទូទាត់ភាគលាភ។

៣-ក្រុមប្រឹក្សាភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រអាចកំណត់កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភដូចគ្នា ឬខុសគ្នាទៅនឹងកាលបរិច្ឆេទកំណត់ទុកនៃមហាសន្និបាតភាគហ៊ុនិក។ ករណីក្រុម-ប្រឹក្សាភិបាលកំណត់កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភដូចគ្នាទៅនឹងកាលបរិច្ឆេទកំណត់ទុកនៃមហាសន្និបាតភាគហ៊ុនិក បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវរៀបចំបញ្ជីឈ្មោះភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភ និងមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិកជាបញ្ជីតែមួយ។

ករណីក្រុមប្រឹក្សាភិបាលកំណត់កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភខុសគ្នាទៅនឹងកាល-បរិច្ឆេទកំណត់ទុកនៃមហាសន្និបាតភាគហ៊ុនិក ក្រុមប្រឹក្សាភិបាលត្រូវធ្វើការកំណត់កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីមានការសម្រេចរបស់មហា-

សន្និបាតភាគហ៊ុនិក និងត្រូវរៀបចំបញ្ជីឈ្មោះភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភ និងមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិកជាបញ្ជីពីរផ្សេងគ្នា។

៤-បុគ្គលចុះបញ្ជីលក់មូលបត្រដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវរៀបចំបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភនៅកាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ។ បុគ្គលចុះបញ្ជីលក់មូលបត្រដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមដល់ភាគហ៊ុនិកទាំងអស់ដែលមានសិទ្ធិទទួលបានភាគលាភ ដូចមានកំណត់ក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ។

៥-បុគ្គលចុះបញ្ជីលក់មូលបត្រដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវពន្យល់ដល់ភាគហ៊ុនិកឱ្យបានច្បាស់លាស់ថា÷

-បញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ គឺជាបញ្ជីឈ្មោះផ្លូវការដែលបានមកពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើង ២ (ពីរ) ថ្ងៃនៃថ្ងៃជួញដូរ មុនកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ។

-ភាគហ៊ុនិកដែលលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួន ១ (មួយ) ថ្ងៃនៃថ្ងៃជួញដូរមុនកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ ឬនៅកាលបរិច្ឆេទអិចឌីវីដឺនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right) នៅតែមានសិទ្ធិទទួលបានភាគលាភ។

-ភាគហ៊ុនិកដែលទិញមូលបត្រកម្មសិទ្ធិ ១ (មួយ) ថ្ងៃនៃថ្ងៃជួញដូរមុនកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភឬនៅកាលបរិច្ឆេទអិចឌីវីដឺនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right) មិនមានសិទ្ធិទទួលបានភាគលាភឡើយ។

៦-បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវកំណត់កាលបរិច្ឆេទចាប់ផ្ដើម និងកាលបរិច្ឆេទបញ្ចប់ការទូទាត់ភាគលាភជូនភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ។

ករណីកាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ និងកាលបរិច្ឆេទកំណត់ទុកនៃមហាសន្និបាតភាគហ៊ុនិកដូចគ្នា ការទូទាត់ភាគលាភជាសាច់ប្រាក់ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមានការសម្រេចរបស់ភាគហ៊ុនិកលើការបែងចែកភាគលាភ ឬករណីកាលបរិច្ឆេទកំណត់ទុកទាំងពីរខុសគ្នា ការទូទាត់ភាគលាភជាសាច់ប្រាក់ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ។

ការទូទាត់ភាគលាភជាមូលបត្រត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់នីតិវិធីនៃការរក្សាទុកមូលបត្រស្របតាមបទប្បញ្ញត្តិដែលមានជាធរមាន។

៧- បុគ្គលចុះបញ្ជីលក់មូលបត្រដោយមានជំនួយពីភ្នាក់ងារទូទាត់ត្រូវធ្វើការទូទាត់ភាគលាភជូនភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភស្របតាមកាលបរិច្ឆេទទូទាត់ភាគលាភដូចបានកំណត់ក្នុងចំណុចទី៦ ខាងលើ។

៨- បុគ្គលចុះបញ្ជីលក់មូលបត្រដោយមានជំនួយពីភ្នាក់ងារទូទាត់ ត្រូវផ្តល់របាយការណ៍ស្តីពីការទូទាត់ភាគលាភជូន ន.ម.ក. ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបញ្ចប់រយៈពេលនៃការទូទាត់ភាគលាភ។

**និយ័តករមូលបត្រកម្ពុជា**